ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៩៣៣ /២៤-១០-២០១៣

សាលដីកា

លេខ:១៨ក្រVI(ធ)/១១-០៤-២០១៤

# នាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាវសៀលថ្ងៃទី១១-០៤-២០១៤ ដែលមានសមាសភាពដូចតទៅ:

<u>សមាសភាពក្រុមប្រឹក្សា</u>

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៩៣៣ ចុះថ្ងៃទី២៤-១០-២០១៣៖

១-ជនជាប់ចោទឈ្មោះ [redacted] មិនា ហៅ [redacted] គីមហុង ហៅ ម៉ាច់ ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរបើកឡានដឹកឥវ៉ាន់ កើតនៅភូមិកំពង់ត្រយ៉ង ឃុំពួក ស្រុកពួក ខេត្តសៀមរាប ទីលំនៅមុនពេលចាប់ [redacted] ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] គ្មានកូន ទោសពីមុនគ្មាន កំរិតវប្បធម៌ថ្នាក់ទី១០ថ្មី ។ ចាប់ខ្លួនថ្ងៃទី៣០.១០.២០១២ ឃុំខ្លួនថ្ងៃទី០១.១១.២០១២ (មិនប្តឹងឧទ្ធរណ៍)

ត្រូវជាប់ចោទពីបទ:ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប និងប្រព្រឹត្តនៅភូមិវត្តពោធិ៍ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីដើមឆ្នាំ២០១២ ដល់ថ្ងៃទី៣០.១០.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងពីបទ:ប្រើប្រាស់លិខិតក្លែង ប្រព្រឹត្តនៅភូមិវត្តពោធិ៍ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី៣០.១០.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិ<u>មាត្រា៦២៨ នៃក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០.១១.២០០៩ ។ល។</u>/

២-ជនជាប់ចោទឈ្មោះ[redacted] វឌ្ឍា ហៅ ក្រូច ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរទាហាន កើតនៅភូមិកំពង់ថ្កូវ ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប [redacted] សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ [redacted]ស) នៅលីវ ទោសពីមុនគ្មាន កំរិតវប្បធម៌ថ្នាក់ទី១២ថ្មី ។ ចាប់ខ្លួនក្នុងសំណុំរឿងមួយផ្សេងទៀត ឃុំខ្លួនថ្ងៃទី ០២.៥.២០១២ (ប៊្លុងឧទ្ទរណ៍)

មានមេធាវីលោក[redacted]ខន្ធា ការពារ

ត្រូវជាប់ចោទពីបទៈផ្ទួញផ្ទូរដោយខុសច្បាប់នូវសារធាតុញៀន, ធាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប និងប្រព្រឹត្តនៅភូមិវត្តពោធិ៍ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីដើម ឆ្នាំ ២០១២ ដល់ថ្ងៃទី៣០.១០.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ ចំណុច១ មាត្រា៤២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ជនជាប់ចោទឈ្មោះ[redacted]ពុធបញ្ញា ហៅ តៅ ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរផាងកាត់សក់ កើតនៅសង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ [redacted] សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន កំរិតវប្បធម៌ថ្នាក់ទី១២ថ្មី ។ (ក្រៅឃុំ)

៤-ជនជាប់ចោទឈ្មោះ[redacted]សុខលី ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបររត់តាក់ស៊ី កើតនៅភូមិដូនតន្ត្រី ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ទីលំនៅសព្វថ្ងៃភូ[redacted] ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ[redacted] គ្មានកូន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

៥-ជនជាប់ចោទឈ្មោះ [redacted] ល័ក្ខណា ហៅ កា ភេទស្រី អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរអ៊ុតសក់ កើតនៅភូមិកោះរាក់ ស្រុកកៀនស្វាយ ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃភូ[redacted] ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ[redacted]រ) នៅលីវ ទោសពីមុនគ្មាន កំរិតវប្បធម៌ថ្នាក់ទី១០ថ្មី ។ (ក្រៅឃុំ, កំពុងនៅក្នុងមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប )

ត្រូវជាប់ចោទពីបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប និងប្រព្រឹត្តនៅភូមិវត្តពោធិ៍ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីដើមឆ្នាំ ២០១២ ដល់ថ្ងៃទី៣០.១០.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។

ឯរឿងហេតុមានដូចតទៅ

ឈ្មោះ [redacted] មិនា ហៅ [redacted] គីមហុង ហៅ ម៉ាច់ បានទិញថ្នាំញៀនប្រភេទម៉ាទឹកកកពីឈ្មោះ [redacted] វឌ្ឍនា ហៅ ក្រូច, ឈ្មោះ ទី, ឈ្មោះ ចឺ និងឈ្មោះ ហឿង យកមកចែកឲ្យឈ្មោះ [redacted] ម៉ាលីកា ហៅ ទូច, [redacted] ពុទ្ធបញ្ញា ហៅ តៅ, [redacted] លក្ខណា ហៅ កា និងឈ្មោះ [redacted] សុខលី ប្រើប្រាស់ ។ នៅថ្ងៃទី៣០.១០.២០១២ វេលាម៉ោង១៦និង២០នាទីល្ងាច សមត្ថកិច្ចនៃការិយាល័យនគរបាលព្រហ្មទណ្ឌកិរិតធ្ងន់នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានឃាត់ខ្លួនឈ្មោះ [redacted] មិនា ហៅ [redacted] គីមហុង, [redacted] ម៉ាលីកា, [redacted] ពុទ្ធបញ្ញា, [redacted] លក្ខណា និងឈ្មោះ [redacted] សុខលី នៅផ្ទះសំណាក់សាគូរ៉ា ស្ថិតនៅភូមិវត្តបូព៌ សង្កាត់ សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប និង ឆែកឆេររកឃើញឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយ ចំនួន ។ នៅពេលឃាត់ខ្លួនឈ្មោះ [redacted] មិនា ហៅ [redacted] គីមហុង សមត្ថកិច្ចបានឆែកឆេររកឃើញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួន២សន្លឹកទៀត មានលេខៈ១៨០២៨៥៥៣០ ចុះថ្ងៃទី២៣.៤.២០១០ ជា របស់ឈ្មោះ [redacted] គីមហុង ប៉ុន្តែអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទាំង២នេះគឺមានរូបថតរបស់ឈ្មោះ [redacted] មិនា តែមួយ និងមានសំបុត្របញ្ជាក់កំណើត(ច្បាប់ចម្លង) របស់ឈ្មោះ [redacted] មិនា ចំនួន១សន្លឹក ។ នៅព្រឹកថ្ងៃទី ០១.១១.២០១២ លោក [redacted] សុខុន ជាព្រះរាជអាជ្ញារង បានសម្រេចឲ្យឈ្មោះ [redacted] ម៉ាលីកា និងឈ្មោះ [redacted] លក្ខណា ទៅកែប្រែខ្លួននៅក្នុងមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៃស្នងការដ្ឋាននគរបាល ខេត្តសៀមរាប ។

រឿងក្តីនេះសាលាដំបូងខេត្តសៀមរាប បានសម្រេចសេចក្តីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខៈ ៤៣(ញ) ចុះថ្ងៃទី៧-៨-២០១៣ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោមៈ

១-ផ្តន្ទាទោសៈ

ក.ឈ្មោះ [redacted] មិនា ហៅ [redacted] គីមហុង ហៅ ម៉ាច់ ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់២(ពីរ)ឆ្នាំ តែទោសនេះត្រូវញែកជាពីរៈ

-ទោសជាប់ពន្ធនាគារកំណត់១០(ដប់)ខែ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០១.១១.២០១២ ។

-ទោសដែលនៅសល់ត្រូវព្យួរទោសធម្មតា ។

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប និងប្រព្រឹត្តនៅភូមិវត្តពោធិ៍ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីដើមឆ្នាំ២០១២ ដល់ថ្ងៃទី៣០.១០.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា១០៧,មាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

ខ.ឈ្មោះ [redacted] វឌ្ឍនា ហៅ ក្រូច ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣(បី) ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០២.៥.២០១៣ ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប និងប្រព្រឹត្តនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ។/

ខេត្តសៀមរាបកាលពីដើមឆ្នាំ២០១២ ដល់ថ្ងៃទី៣០.១០.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ.ឈ្មោះ [redacted] ពុធបញ្ញា ហៅ តៅ ភេទប្រុស អាយុ២៥ឆ្នាំ, ឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ៣២ឆ្នាំ និងឈ្មោះ [redacted] លក្ខណា ហៅ កា ភេទស្រី អាយុ១៩ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់កំណត់៣(បី)ខែ តែទោសនេះត្រូវអនុវត្តព្យួរទោសធម្មតា ។

ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប និងប្រព្រឹត្តនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីដើមឆ្នាំ២០១២ ដល់ថ្ងៃទី៣០.១០.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។

ង-ក.ឱ្យឈ្មោះ [redacted] មិនា ហៅ [redacted] គីមហុង ហៅ ម៉ាច់ ភេទប្រុស អាយុ៣២ឆ្នាំ រួចខ្លួនពីបទ ប្រើប្រាស់ លិខិតក្លែង ប្រព្រឹត្តនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី៣០.១០.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦២៨ នៃក្រមព្រហ្មទណ្ឌ ។

ខ.ឱ្យឈ្មោះ [redacted] វឌ្ឍនា ហៅ ក្រុច ភេទប្រុស អាយុ៣២ឆ្នាំ រួចខ្លួនពីបទ ផាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុងសៀមរាប ខេត្តសៀមរាប និងប្រព្រឹត្តនៅភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីដើមឆ្នាំ២០១២ កាលពីថ្ងៃទី៣០.១០.២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ដែលចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ តាមដីកាលេខៈ៥៧៧០ ពស.ព្រទ/២០១៣ ចុះថ្ងៃទី៧.៦.២០១៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប តាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥០, មាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មិនា ហៅ [redacted] គីមហុង ហៅ ម៉ាច់, ឈ្មោះ [redacted] វឌ្ឍនា ហៅ ក្រុច និងកំបាំងមុខឈ្មោះ [redacted] ពុធបញ្ញា ហៅ តៅ, ឈ្មោះ [redacted] សុខលី និងឈ្មោះ [redacted] លក្ខណា ហៅ កា ។ ទុកសិទ្ធិឱ្យប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

សេចក្តីសម្រេចនៃសាលក្រមនេះត្រូវបានឈ្មោះ [redacted] វឌ្ឍនា ប្តឹងឧទ្ធរណ៍ចុះថ្ងៃទី៤.៩.២០១៣ ត្រង់ចំណុចទី១(ខ) នៃសេចក្តីសម្រេច ។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី២៥.០១.២០១៤ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍

បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ របស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសម្រេចរឿងក្តី.../

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណធា ហៅ ក្រុច ឆ្លើយថាៈ ខ្លួនមិនសុខចិត្តប្តឹងឧទ្ធរណ៍ ព្រោះខ្លួនមិនបានប្រព្រឹត្តទេ ហើយនៅពេលសវនាការនៅសាលាដំបូងខេត្តសៀមរាប ពួកគេក៏មិនបានឆ្លើយដាក់ខ្លួនដែរ ពួកគេថាមិនស្គាល់ខ្លួនទេ និង មិនដែលទាក់ទងគ្នាទេ ។ ឈ្មោះ [redacted] ទី ជាអ្នកជួញដូរគ្រឿងញៀន ធ្លាប់តទល់មុខគ្នាហើយ ឈ្មោះ [redacted] ទី ថាមិនដែលទាក់ទងខ្លួន និង យកគ្រឿងញៀនពីខ្លួនទេ ។ ពេលសមត្ថកិច្ចឃាត់ខ្លួនអត់មានអ្វីនៅនឹងខ្លួនទេ ។ ពីមុនមិនដែលជួញដូរគ្រឿងញៀនទេ តែធ្លាប់ប្រើប្រាស់គ្រឿងញៀនតែឈប់ហើយ ព្រោះប៉ាគាត់យកទៅបន្សាបនៅខេត្តបន្ទាយមានជ័យ ។ ខ្លួនមិនស្គាល់ពួកគេដែលចូលមកក្នុងពេលសវនាការទេ ។ ខ្លួនសំណូមពរសុំឱ្យលើកលែងទោសដល់ខ្លួន ។

-តំណាងមហាអយ្យការសន្និដ្ឋានថាៈ មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ពីបទជួញដូរ និងប្រើប្រាស់សារធាតុញៀន ហេតុសុំឱ្យតំកល់សេចក្តីសម្រេចសាលក្រមរបស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល ។

-មេធាវី [redacted] ចន្ថា ការពារជនជាប់ចោទសន្និដ្ឋានថាៈ ពេលនេះក៏ដូចនៅពេលសវនាការសាលាដំបូង កូនក្តីខ្លួនបានឆ្លើយបដិសេធរហូត ថាមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ចំលើយជនជាប់ចោទផ្សេងៗទៀតថាមិនមែនឈ្មោះ ក្រុច កូនក្តីខ្លួននេះទេ មិនដឹង ក្រុច ណាទេ ក្រុចពេលនេះមិនមែនជា ក្រុច ដែលជួញដូរគ្រឿងញៀនទេ ។ ហេតុនេះសុំឱ្យកូនក្តីខ្លួនបានរួចផុតពីបទចោទ ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិនិត្យលើឯកសារដែលពាក់ពន្ធ័

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សាលាឧទ្ធរណ៍

យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៤-០៩-២០១៣ របស់ឈ្មោះ [redacted] វណ្ណធា ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា៣៧៥ និង៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ក្នុងរឿងក្តីនេះគឺមានតែឈ្មោះ [redacted] វណ្ណធា ហៅ ក្រុច ម្នាក់ទេដែលមានប្តឹងឧទ្ធរណ៍ ដូច្នេះសាលាឧទ្ធរណ៍លើកយកតែករណីឈ្មោះ [redacted] វណ្ណធា នេះមកធ្វើការពិចារណាតែប៉ុណ្ណោះ ។

៣-ជនជាប់ចោទឈ្មោះ [redacted] វណ្ណធា ហៅ ក្រុច បានឆ្លើយបដិសេធថា ខ្លួនពុំបានប្រព្រឹត្តអំពើជួញដូរគ្រឿងញៀន និង មិនបានប្រើប្រាស់គ្រឿងញៀន ដូចការចោទប្រកាន់នោះទេ ។ ប៉ុន្តែតាមចម្លើយសួរតទល់រវាងឈ្មោះ [redacted] ទី និង ជនជាប់ចោទឈ្មោះ [redacted] វណ្ណធា ហៅ ក្រុច នៅចំពោះមុខចៅក្រមស៊ើបសួរ ឈ្មោះ [redacted] ទី បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ថាឈ្មោះ [redacted] វណ្ណធា នៅចំពោះមុខខ្លួននេះមានឈ្មោះហៅក្រៅ

ថា ក្រេច ហើយខ្លួនធ្លាប់បានទូរស័ព្ទទៅទិញគ្រឿងញៀនពីគាត់០២ទៅ០៣ដង ដូច្នេះបញ្ជាក់អោយឃើញថាជនជាប់ចោទឈ្មោះ [redacted] វណ្ណធា នេះពិតជាបានជួញដូរគ្រឿងញៀនប្រាកដមែន ។

៤-តាមចម្លើយរបស់ឈ្មោះ [redacted] ល័ក្ខណា ហៅ កា បានបញ្ជាក់ថាខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនជាមួយឈ្មោះ ក្រេច នៅផ្ទះសំណាក់ ដូច្នេះបញ្ជាក់អោយឃើញថាជនជាប់ចោទឈ្មោះ [redacted] វណ្ណធា ហើយ ក្រេច ពិតជាបានប្រើប្រាស់គ្រឿងញៀនប្រាកដមែន ។

៥-មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] វណ្ណធា ហើយ ក្រេច ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្រុងសៀមរាប កាលពីដើមឆ្នាំ២០១២ ដល់ថ្ងៃទី៣០-១០-២០១២ បទល្មើសព្រហ្មទណ្ឌដែល មានចែងអោយផ្តន្ទាទោសតាមមាត្រា ៤០ និង ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦-សាលក្រមព្រហ្មទណ្ឌលេខៈ៤៣(ញ) ចុះថ្ងៃទី០៧-០៨-២០១៣ របស់សាលាដំបូងខេត្តសៀមរាប ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៩-០៨-២០១៣ របស់ឈ្មោះ [redacted] វណ្ណធា ទុកថាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៤៣(ញ) ចុះថ្ងៃទី០៧-០៨-២០១៣ របស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល ។

៣-សាលដីការនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹង សាទុក្ខ តាមកំណត់ច្បាប់ ។/

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

ក្រឡាបញ្ជី
ហត្ថលេខា [redacted]

ចៅក្រមប្រឹក្សា
ហត្ថលេខា [redacted], [redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា [redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 22 ខែ 5 ឆ្នាំ២០14
ក្រឡាបញ្ជី
[redacted]